**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

## សាររំលែកមរណទុក្ខ

**ជូនចំពោះ**
**ឯកឧត្តម សំ ព្រហ្មនី និងក្រុមគ្រួសារ**

**ឯកឧត្តម** ជាទីរាប់អាន!

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃក្រសួងមុខងារសាធារណៈ មានសេចក្តីក្រៀមក្រំ និងសោកស្តាយជាពន់ពេក ដោយបានទទួលដំណឹងថា **ឯកឧត្តម សំ ព្រហ្មនា** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវជាឪពុករបស់ **ឯកឧត្តម សំ ព្រហ្មនី** បានទទួលមរណភាពកាលពីថ្ងៃសុក្រ ៣រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ១៣:០០នាទី ក្នុងជន្មាយុ ៨១ឆ្នាំ ដោយរោគាពាធ។

ក្នុងបរិយាកាសប្រកបដោយក្តីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្តែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្តាយជាទីបំផុតជាមួយ **ឯកឧត្តម សំ ព្រហ្មនី និងក្រុមគ្រួសារ** ចំពោះការបាត់បង់ដ៏ធំធេង មិនអាចរកអ្វីមកប្រៀបបានមួយនេះ។

ការបាត់បង់ **ឯកឧត្តម សំ ព្រហ្មនា** ជាការបាត់បង់នូវវៃស្សរជន និងធនធានមនុស្សមួយរូបដែលតែងតែបានពុះពារលះបង់អស់កម្លាំងកាយចិត្ត ធនធានប្រាជ្ញាស្មារតី ក្នុងការបម្រើប្រទេសជាតិ រួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍជាតិមាតុភូមិនាពេលកន្លងមក។

ខ្ញុំសូមឧទ្ទិសបួងសួងជូនដួងវិញ្ញាណក្ខន្ធ **ឯកឧត្តម សំ ព្រហ្មនា** បានអញ្ជើញទៅកាន់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម សំ ព្រហ្មនី និងក្រុមគ្រួសារ** ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំពីយើងខ្ញុំ។

ថ្ងៃចន្ទ ៦ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ សីហា ឆ្នាំ២០២៣

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រុំ.សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh